ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ០៤៣/១៥ ក.អ.ជ.ប្រក

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ មាឃ ឆ្នាំ មមី ព.ស.២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ គ.ស ២០១៥

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ជូនរដ្ឋបាលស្រុកឈូក ស្រុកជុំគិរី ស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាច នៃខេត្តកំពត និងស្រុកមេមត់ ស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារ នៃខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាល ក្រុង ស្រុក


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញសេចក្តីសម្រេចលេខ ១០៣ សសរ/គ.ជ.អ.ប ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការកំណត់ស្រុកគោលដៅសម្រាប់អនុវត្តគម្រោងសាកល្បងស្តីពីការផ្ទេរមុខងារជួសជុលថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារ "ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ" ឱ្យដល់រដ្ឋបាលស្រុកឈូក ស្រុកជុំគីរី ស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាចនៃខេត្តកំពត និងស្រុកមេមត់ ស្រុកត្បូងឃ្មុំ និងស្រុកក្រូចឆ្មារនៃខេត្តត្បូងឃ្មុំ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តសាកល្បង ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ គឺចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៦។

**ប្រការ ២.-**

មុខងារ **ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ** រួមមាន៖

- ការជួសជុលតូច និងការជួសជុលធំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដូចជា៖ អណ្តូងស្នប់ អណ្តូងលូ អណ្តូងចម្រុះ ស្រះសហគមន៍ និងបណ្តាញចែកចាយទឹកតាមទុយោរបស់សហគមន៍
- ការធ្វើតេស្តគុណភាពទឹកដោយប្រើឧបករណ៍យួរដៃតូចៗ
- គាំទ្រដល់ដំណើរការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
- ពង្រឹងសមត្ថភាពក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យក្នុងការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងអស់ក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុក។

**ប្រការ ៣.-**

នីតិវិធីនៃការគ្រប់គ្រង និងបច្ចេកទេសនៃការអនុវត្តមុខងារដែលត្រូវធ្វើប្រតិភូកម្ម ត្រូវអនុវត្តតាមសេចក្តីណែនាំស្តីពីការជួសជុល និងការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដែលកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។

**ប្រការ ៤.-**

នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ត្រូវសហការជាមួយនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងមន្ទីរអភិវឌ្ឍន៍ជនបទនៃខេត្តទាំងពីរ ដើម្បីកំណត់ទំហំថវិកាសម្រាប់ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទក្នុងស្រុកគោលដៅដូចមានចែងក្នុងប្រការ ១ ដោយប្រើប្រាស់ប្រភពថវិកាតាមកម្មវិធីដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

យន្តការនៃផ្ទេរថវិកាពីក្រសួងអភិវឌ្ឍន៍ជនបទទៅរដ្ឋបាលស្រុកគោលដៅ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការអនុវត្តមុខងាររវាងក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលស្រុកគោលដៅ។

រដ្ឋបាលស្រុកអាចចូលរួមមូលនិធិបដិភាគពីចំណូលផ្ទាល់របស់ខ្លួន ដើម្បីអនុវត្តមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ដោយផ្អែកលើសមត្ថភាពហិរញ្ញវត្ថុរបស់ស្រុក និងសេចក្តីត្រូវការក្នុងការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។

**ប្រការ ៥**.-

ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ត្រូវចាត់តាំងមន្ត្រីជំនាញ និងមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលស្រុកគោលដៅក្នុងរយៈពេលអនុវត្តសាកល្បងនេះ។

**ប្រការ ៦**.-

ក្នុងកំឡុងពេលអនុវត្តមុខងារសាកល្បង រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវដូចតទៅ÷

- ពិនិត្យជាទៀងទាត់នូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទដោយសហការជាមួយក្រុមប្រឹក្សាឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
- បញ្ចូលក្នុងកម្មវិធីវិនិយោគរបស់ស្រុកនូវផែនការ និងថវិកាប្រចាំឆ្នាំ ដើម្បីជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- គ្រប់គ្រង និងចាត់ចែងថវិកាសម្រាប់ការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ដឹកនាំធ្វើលទ្ធកម្មដើម្បីទិញគ្រឿងបន្លាស់ និងលើការជួសជុលធំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទស្រប តាមនីតិវិធីលទ្ធកម្មដែលមានស្រាប់របស់រដ្ឋបាល ក្រុង ស្រុក
- ត្រួតពិនិត្យគុណភាពទឹករៀងរាល់ ៦ ខែម្តង ដោយប្រើប្រាស់ឧបករណ៍ធ្វើតេស្ត។ បើមានការសង្ស័យអំពីគុណភាពទឹក ត្រូវរាយការណ៍ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- ផ្តល់ការគាំទ្រដល់ដំណើរការបង្កើតក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
- ពង្រឹងសមត្ថភាពដល់ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យក្នុងការថែទាំ និងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- គ្រប់គ្រងទិន្នន័យ និងបញ្ជីសារពើភ័ណ្ឌប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទក្នុងដែនសមត្ថកិច្ច
- សហការជាមួយភាគីពាក់ព័ន្ធដើម្បីតាមដាន និងត្រួតពិនិត្យ អ្នកម៉ៅការឯកជនដែលបានទទួលកិច្ចសន្យាផ្តល់សេវាជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- រៀបចំវេទិកាប្រចាំឆ្នាំជាសាធារណៈស្តីពីការផ្គត់ផ្គង់ទឹកស្អាតជនបទក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីកសាងផែនការឆ្នាំបន្ទាប់
- ធ្វើរបាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពនៃការអនុវត្តមុខងារជូនក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។

**ប្រការ ៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានផ្គត់ផ្គង់និង ហិរញ្ញវត្ថុ នាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាតជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកពាក់ព័ន្ធ ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកពាក់ព័ន្ធ ត្រូវអនុវត្ត ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជា សុផារ៉ា**

<u>កន្លែងទទួល</u> ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- សាលាខេត្តកំពត និងខេត្តត្បូងឃ្មុំ

*" ដើម្បីជូនជ្រាប "*

- សាលាស្រុកគោលដៅ
- ដូចប្រការ ៨

*" ដើម្បីអនុវត្ត "*

- ឯកសារ កាលប្បវត្តិ